# ជួប សេបគ្រែម មកពីប្រទេសកម្ពុជា

*សូមជួបកុមារអង្គការបឋមសិក្សាដែលកំពុងជួយអ្នកដទៃ ដូចព្រះគ្រីស្ទបានធ្វើ ។*



## រឿងលម្អិតអំពី សេបគ្រែម



ភាសា ៖
ភាសាខ្មែរ ភាសាអង់គ្លេស

អាយុ ៖
១២ឆ្នាំ

មកពី ៖
ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។

គោលដៅ និងក្តីសុបិន ៖
១) ជួយប្រទេសកម្ពុជាឲ្យក្លាយជាប្រទេសដ៏ល្អប្រសើរនៅពេលខ្ញុំធំឡើង ។
២). បម្រើបេសកកម្ម ។
៣) ទៅព្រះវិហារបរិសុទ្ធ ។



គ្រួសារ ៖
សេបគ្រែម ម្ដាយ ឪពុក បងប្អូនស្រីពីរនាក់ ប្អូនប្រុសម្នាក់

រចនារូបភាពដោយ លីសា ហាន់



## ដៃជំនួយរបស់សេបគ្រែម

សេបគ្រែម ទៅសាលារៀននៅក្នុងទីក្រុងធំមួយ ។ ពេលខ្លះនៅសាលារៀន គាត់បានកត់សម្គាល់ឃើញថា មានមិត្តខ្លះពុំមានអាហារគ្រប់គ្រាន់ទេ ។ ដូច្នេះគាត់បានចែកចាយអាហារសម្រន់និងអាហារថ្ងៃត្រង់របស់គាត់ជាមួយពួកគេ ។ សេបគ្រែម និយាយថាការជួយអ្នកដទៃធ្វើឲ្យគាត់មានអារម្មណ៍ល្អ ។ គាត់បាននិយាយថា « វាធ្វើឲ្យខ្ញុំចង់ធ្វើបន្ថែមទៀត ។ ខ្ញុំមានអារម្មណ៍រីករាយ នៅពេលខ្ញុំធ្វើតាមព្រះយេស៊ូវ » ។

សេបគ្រែម និយាយថា យើងត្រូវបានប្រទានពរ នៅពេលយើងបម្រើអ្នកដទៃ ។ « នៅពេលយើងធ្វើអ្វីមួយល្អ នោះព្រះនឹងប្រទានពរដល់យើង ។ ព្រះយេស៊ូវមានបន្ទូលថា ការធ្វើល្អដល់មនុស្សដទៃទៀត គឺដូចជាធ្វើល្អដល់ទ្រង់ដែរ » ។ ●



សេបគ្រែម ធ្វើតាមព្រះយេស៊ូវដោយការចែករំលែកជាមួយនឹងអ្នកដទៃ ។ សូមបើកទំព័រ ដើម្បីអានរឿងមួយអំពីរបៀបដែលព្រះយេស៊ូវបានប្រទានអាហារដល់អ្នកស្រេកឃ្លាន ។

## ចំណូលចិត្តរបស់សេបគ្រែម



ដំណើររឿងអំពីព្រះយេស៊ូវ ៖
នៅពេលទ្រង់បានជួយពេត្រុសឲ្យដើរនៅលើទឹក



ទីកន្លែង ៖
គេហដ្ឋាន



ចម្រៀងកុមារ ៖
« ខ្ញុំជាកូនរបស់ព្រះ »
( *សៀវភៅចម្រៀងកុមារលេខ២-៣* )



អាហារ ៖
អាម៉ុក ( ត្រីចម្អិនក្នុងស្លឹកចេក )

ពណ៌ ៖
ខៀវ

មុខវិជ្ជានៅសាលា ៖
អង់គ្លេស និងប្រវត្តិសាស្ត្រ



### សូមចូលរួមក្រុមដៃជំនួយ !



*នៅពេលប្អូនបម្រើអ្នកដទៃ ប្អូនគឺជាផ្នែកនៃក្រុមដៃជំនួយ ! តើប្អូនអាចបម្រើនរណា ?*